

# លោកតាតន្ត្រី

Let's Read
The Asia Foundation



លោកតាតន្ត្រីមានច្រមុះវែង ហើយគាត់មានភ្នែកមូលធំៗ។ គាត់ពាក់អាវពណ៌ឥន្ទធនូ ហើយរាល់ពេលដែលគាត់បើកមាត់ យើងតែងតែឮចង្វាក់ភ្លេង។ សួស្តីចៅៗ! លោកតាចូលចិត្តច្រៀង ហើយលោកតាអាចច្រៀងរាល់ថ្ងៃ។



ជារៀងរាល់ថ្ងៃ លោកតានិយាយអរុណសួស្តីទៅកាន់មនុស្សគ្រប់រូបៗ! ឈប់ងងុយគេងហើយ...លោកតាយល់សប្តិថា លោកតាគូររូបគំនូរ និងឃើញឆ្មារោមពណ៌លឿងជាច្រើនក្បាល។





លោកតាក្រោកពីព្រឹកព្រលឹម។ គាត់ដើរកាត់ស្មៅ ហើយ
និយាយទៅកាន់ស្មៅខ្ចីៗថា ពួកឯងលូតលាស់បានល្អណាស់
ពីពន្លកតូចៗទៅជាស្មៅខៀវល្អៗ។ ដូចខ្ញុំដែរ នៅពេលដែលឯង
នៅក្រោមមេឃស្រឡះ ឯងអាចដកដង្ហើមបានល្អ និងនាំមកនូវ
ភាពរីករាយ។



តើលោកតាអាចនឹកឃើញទំនុកច្រៀងទាំងអស់នេះបាន
យ៉ាងដូចម្ដេច? អស់ពីមួយចូលមួយទៀត៖
ពួកគេរស់នៅជាមួយគ្នាដូចអ្នកហើយនឹងខ្ញុំ និងសត្វលលក
ដែលស្រែកច្រៀងនៅលើមែកឈើ និងអំឡុងពេលកណ្ដូប
លោតចុះឡើង។ ពួកយើងគឺជាគ្រួសារធំមួយ!



បន្ទាប់ពីស្វាគមន៍ធម្មជាតិរួចរាល់ លោកតាពាក់មួកស្បូវរបស់គាត់ ដែលមានស្ករគ្រាប់យោលនៅជាយមួករបស់គាត់។ មិត្តភក្តិរបស់គាត់ចាប់ផ្តើមចូលរួមដំណើរជាមួយ។ សត្វទីទុយហោះមកមុនគេ។ វាចូលចិត្តបេះស្ករពីជាយមួករបស់លោកតា។

លោកតានិយាយថា៖ អរុណសួស្តី! អរុណសួស្តីមិត្តភក្តិតូចៗរបស់ខ្ញុំ! បានឃើញឯងទុកជាសំណាងរបស់ខ្ញុំហើយ! ខ្ញុំបានបង្កើតមិត្តភក្តិល្អ សូម្បីតែមួកខ្ញុំក៏ផ្អែមដែរ។



តើអ្នកដឹងទេថាមានអ្នកណាផ្សេងទៀតដែលចូលរួមដំណើរជាមួយលោកតា? កូនសត្វដំរីតូច សដូចព្រិលទឹកកក! ពួកគេចាប់ផ្ដើមដំណើរកំសាន្តទាំងអស់គ្នា ដោយឆ្លងកាត់ភូមិមួយចំនួន។

អ្នកភូមិចាំដំណើរឆ្លងកាត់របស់លោកតាជាមួយមិត្តភក្តិគាត់យ៉ាងអន្ទះសា។ ពួកគេចូលចិត្តស្តាប់ទំនុកច្រៀងរបស់លោកតា ៖ ខ្ញុំដើរ! ខ្ញុំច្រៀង! ខ្ញុំដើរ! ខ្ញុំច្រៀង!



ទីទុយស្រែក ”កុំឈប់ៗ ច្រៀងទៀតៗ” លោកតាបន្ត មិនថា ឯងគិតយ៉ាងណា ”ពួកយើង ចាស់ ចម្លែក ប៉ុន្តែឆ្លាត។ ពួកយើងមានវេទមន្ត ឃើញអត់?” កូនដំរីរាំតាមទំនុកច្រៀង ហើយនិយាយថា ”តោះ! ចាប់ផ្តើមដំណើរផ្សងព្រេង។”



ដំណើរផ្សងព្រេងនៅលើសមុទ្រចាប់ផ្តើម! លោកតាជិះលើត្រីបាឡែន ហើយស្រែកច្រៀង៖ ចៅៗទាំងអស់គ្នា យកស្ករទាំងអស់នេះទៅញុាំ ប្រយ័ត្នកុំឱ្យធ្លាក់ចូលទឹក!



ដំណើរផ្សងព្រេងមួយទៀតគឺនៅលើមេឃ! លោកតាកំពុងតែហោះ! គាត់កំពុងតែតោងទីទុយ ប៉ុន្តែ ”តើឯងបានស្លាបមកពីណា កូនដំរី?” ទាដែលបានហោះកាត់បានសួរ។ តើអ្នកគិតយ៉ាងណាវិញ?



”ហិ ហិ ហូ ហូ!” មិត្តទាំងបីក៏សើច។ លោកតានិយាយ៖ អ្នកដែលសើចអស់ពីចិត្ត អាចធ្វើអ្វីគ្រប់យ៉ាង។ បើមានជំនឿបន្តិចក្តីសង្ឃឹមបន្តិច នោះគ្រប់គ្នានឹងអាចហោះហើរបាន!



នៅតាមផ្លូវទៅផ្ទះ ក្មេងៗនាំគ្នារត់មករកលោកតា។ លោកតា
តែងតែមានចម្រៀងមួយចុងក្រោយ៖



ចៅៗត្រូវយល់ ថ្ងៃណាមួយចៅៗនឹងដឹង ចៅៗត្រូវចំណាយពេលជាមួយចាស់ៗ លោកតាមិនអាចនៅជាមួយជារៀងរហូតទេ។



ព្រឹកមួយ នៅពេលលោកតាក្រោកពីដំណេក គាត់បានឮ
សំឡេងសត្វចង្រិត។ ជាមួយសំឡេងសត្វចង្រិត លោកតា
បង្កើតទំនុកច្រៀងថ្មី៖ ពេលថ្ងៃរះ ចង្រិតច្រៀង ជាចំរៀងដែល
ខ្ញុំចូលចិត្តក្នុងលោកនេះយើងនៅជាមួយគ្នាមិនថាទីនេះ
ខាងក្រោម ឬខាងលើ។



លោកតាមិនបានដើរកាត់ភូមិទេថ្ងៃនោះ។ ក្មេងៗបានរកគាត់គ្រប់ទីកន្លែង ប៉ុន្តែនៅតែមិនរកលោកតាឃើញ។ "តើលោកតាទៅទីណាទៅ?" ពួកគេសួរ។ "អ្នកម៉ាក់! តើម៉ាក់អាចនាំលោកតាមកឲ្យពួកយើងវិញបានទេ? ពួកយើងនឹកចំរៀងរបស់គាត់ណាស់!"



ម្ដាយនិយាយថា ”ប្រហែលជាលោកតាទៅឆ្ងាយហើយ! ប្រហែលគាត់ទៅប្រទេសផ្សេង ដើម្បីចាប់ផ្ដើមដំណើរផ្សងព្រេងថ្មី។”

ម្ដាយច្រៀង៖ គាត់លេងល្បែងថ្មី គាត់ច្រៀងចម្រៀងថ្មីសម្រាប់ក្មេងៗនៅកន្លែងផ្សេង ។ កូនៗនឹងឮសូរក្មេងៗសើច ព្រោះពួកគេមានលោកតានៅជិត។

Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**
*Rhyming Grandpa*, Published by Room to Read, © Room to Read. Released under CC BY 4.0.

This work is a modified version of the original story. © The Asia Foundation, 2020. Some rights reserved. Released under CC BY 4.0.

For full terms of use and attribution,
http://creativecommons.org/licenses/by/4.0/